# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ប្រក

## ប្រកាសរួម
## ស្តីពី
## ការផ្តល់រង្វាន់លើកទឹកចិត្ត
## ជូនក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងរ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរ និងសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជា ទៅក្រោមក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ[illegible] សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញសារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២ .-**

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នារវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើក្របខ័ណ្ឌសមត្ថកិច្ចដែលអនុវត្តប្រមូលចំណូលដោយរដ្ឋបាលកណ្តាល និងការអនុវត្តប្រមូលចំណូលដោយមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ ៣ .-**

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលក្រសួងរ៉ែ និងថាមពល និងមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួន ពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដូចបានកំណត់ដោយប្រកាសរួមលេខ១៤៥៦១សហវ.ប្រក ចុះថ្ងៃទី.០៣ ខែ.វិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថាថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទាន សម្រាប់ការចំណាយដូចបានកំណត់នៅក្នុងប្រការ ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងរ៉ែ និងថាមពល និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៤ .-**

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ទាំងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត) ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូល ដែលប្រមូលបាន ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ ៥ .-**

រដ្ឋបាលកណ្តាលក្រសួងរ៉ែ និងថាមពល និងមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលក្រសួងរ៉ែ និងថាមពល ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទាន សម្រាប់ទូទាត់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ទូទាត់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាផ្ទុះបញ្ចាំងក្នុងថវិកាជាតិដូចកិច្ចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងរ៉ែ និងថាមពល ដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទាន(រង្វាន់ដែលបានកាត់ទុក)ពីចំណូលថវិកាជាតិ។

**ប្រការ ៦ .-**

ការទូទាត់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ÷

**ក. ផ្នែកចំណូល**

ធ្វើសំណើសុំកត់ត្រាចំណូល និងសលាកប័ត្រចំណូលថវិកាជាតិនូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ÷

- **ចំពោះរដ្ឋបាលកណ្តាលក្រសួងរ៉ែ និងថាមពល :** បញ្ជូនសំណើ និងសលាកប័ត្រចំណូលថវិកាជាតិ មកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងស្តីពីការគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។
- **ចំពោះមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត :** បញ្ជូនសំណើ និងសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងស្តីពីការគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ខ. ផ្នែកចំណាយ**

រដ្ឋបាលកណ្តាលក្រសួងរ៉ែ និងថាមពល និងមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវធ្វើសំណើសុំទូទាត់ចំណាយប្រាក់រង្វាន់លើកទឹកចិត្ត និងធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៧ .-**

ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តដូចខាងក្រោម ÷

**ក.** ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងរ៉ែ និងថាមពល ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ខ.** ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ ៨ .-**

និរាករណ៍ទាំងស្រុងប្រកាសរួមលេខ ១០០៦ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥

| | |
|---|---|
| **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងរ៉ែ និងថាមពល** |
| **បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន** | **ស៊ុយ សែម** |

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត

**«ដើម្បីជូនជ្រាប»**

- ដូចប្រការ ៩ **«ដើម្បីអនុវត្ត»**
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១២៤២ សហវ.ប្រក ចុះថ្ងៃទី..០៣... ខែ.វិច្ឆិកា. ឆ្នាំ២០១៥

ស្តីពីការផ្តល់ទ្វាន់លើកទឹកចិត្តជូនក្រសួងរ៉ែ និងថាមពល(ក រថ) និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ក សហវ)

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. រថ | ក. សហវ |
| I. ការផ្តល់សេវាសាធារណៈ | | | | |
| I.១- អគ្គនាយកដ្ឋានធនធានរ៉ែ (អាជ្ញាប័ណ្ណធនធានរ៉ែ) | | | | |
| ក. ការផ្តល់អាជ្ញាប័ណ្ណ | | | | |
| ១ | សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ | ៥០% | ៤៩% | ១% |
| ២ | សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត | ៥០% | ៤៩% | ១% |
| ៣ | លិខិតអនុញ្ញាតបុរេសនា | ៥០% | ៤៩% | ១% |
| ៤ | ផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ | ៥០% | ៤៩% | ១% |
| ៥ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ | ៥០% | ៤៩% | ១% |
| ៦ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម្នាងសិលា និង ថ្មផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ៥០% | ៤៩% | ១% |
| ៧ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្មមានតម្លៃ ទ្រង់ទ្រាយតូច | ៥០% | ៤៩% | ១% |
| ៨ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្មមានតម្លៃ ទ្រង់ទ្រាយធំ | ៥០% | ៤៩% | ១% |
| ៩ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មតិចជាង ៧នាក់ | ៥០% | ៤៩% | ១% |
| ១០ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មពី ៧នាក់ ទៅ ១៤នាក់ | ៥០% | ៤៩% | ១% |
| ១១ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មលើសពី ១៤នាក់ | ៥០% | ៤៩% | ១% |
| ១២ | អាជ្ញាប័ណ្ណស្វែងរុករក | ៥០% | ៤៩% | ១% |
| ១៣ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច | ៥០% | ៤៩% | ១% |
| ១៤ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ | ៥០% | ៤៩% | ១% |
| ខ. ការចុះបញ្ជីអាជ្ញាប័ណ្ណ | | | | |
| ១៥ | អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ | ៥០% | ៤៩% | ១% |
| ១៦ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ | ៥០% | ៤៩% | ១% |
| ១៧ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម្នាងសិលា និង ថ្មផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ៥០% | ៤៩% | ១% |
| ១៨ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្មមានតម្លៃ ទ្រង់ទ្រាយតូច | ៥០% | ៤៩% | ១% |
| ១៩ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្មមានតម្លៃ ទ្រង់ទ្រាយធំ | ៥០% | ៤៩% | ១% |
| ២០ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ | ៥០% | ៤៩% | ១% |
| ២១ | អាជ្ញាប័ណ្ណស្វែងរុករក | ៥០% | ៤៩% | ១% |
| ២២ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច | ៥០% | ៤៩% | ១% |
| ២៣ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ | ៥០% | ៤៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. រថ | ក. សហវ |
| **គ. ការពន្យារបន្តអាជ្ញាប័ណ្ណ** | | | | |
| ២៤ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម៉ាងសិលា និង ថ្មផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ៥០% | ៤៩% | ១% |
| ២៥ | អាជ្ញាប័ណ្ណស្វែងរុករក | ៥០% | ៤៩% | ១% |
| ២៦ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែទ្រង់ទ្រាយធំ | ៥០% | ៤៩% | ១% |
| **ឃ. ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ** | | | | |
| ២៧ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ | ៥០% | ៤៩% | ១% |
| ២៨ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម៉ាងសិលា និង ថ្មផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ៥០% | ៤៩% | ១% |
| ២៩ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃទ្រង់ទ្រាយធំ | ៥០% | ៤៩% | ១% |
| ៣០ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មតិចជាង ៧នាក់ | ៥០% | ៤៩% | ១% |
| ៣១ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មពី ៧នាក់ ទៅ ១៤នាក់ | ៥០% | ៤៩% | ១% |
| ៣២ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មលើសពី ១៤នាក់ | ៥០% | ៤៩% | ១% |
| ៣៣ | អាជ្ញាប័ណ្ណស្វែងរុករក | ៥០% | ៤៩% | ១% |
| ៣៤ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែទ្រង់ទ្រាយធំ | ៥០% | ៤៩% | ១% |
| **ង. ការចេញលិខិតទទួលស្គាល់ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០%)** | | | | |
| ៣៥ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ | ៥០% | ៤៩% | ១% |
| ៣៦ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម៉ាងសិលា និង ថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល | ៥០% | ៤៩% | ១% |
| ៣៧ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ | ៥០% | ៤៩% | ១% |
| ៣៨ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មតិចជាង ៧នាក់ | ៥០% | ៤៩% | ១% |
| ៣៩ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មពី ៧នាក់ ទៅ ១៤នាក់ | ៥០% | ៤៩% | ១% |
| ៤០ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មលើសពី ១៤នាក់ | ៥០% | ៤៩% | ១% |
| ៤១ | អាជ្ញាប័ណ្ណស្វែងរុករក | ៥០% | ៤៩% | ១% |
| ៤២ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ | ៥០% | ៤៩% | ១% |
| **ច. ការចេញលិខិតទទួលស្គាល់ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលចាប់ពី ៥០% ឡើងទៅ)** | | | | |
| ៤៣ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ | ៥០% | ៤៩% | ១% |
| ៤៤ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម៉ាងសិលា និង ថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល | ៥០% | ៤៩% | ១% |
| ៤៥ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ | ៥០% | ៤៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. រថ | ក. សហរ |
| ៤៦ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មតិចជាង ៧នាក់ | ៥០% | ៤៩% | ១% |
| ៤៧ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មពី ៧នាក់ ទៅ ១៤នាក់ | ៥០% | ៤៩% | ១% |
| ៤៨ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មលើសពី ១៤នាក់ | ៥០% | ៤៩% | ១% |
| ៤៩ | អាជ្ញាប័ណ្ណស្វែងរុករក | ៥០% | ៤៩% | ១% |
| ៥០ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ | ៥០% | ៤៩% | ១% |
| ឆ. ការចេញលិខិតបញ្ជាក់សំណាករ៉ែ និងធនធានរ៉ែសម្រាប់គោលបំណងនាំចេញ-នាំចូល | | | | |
| ៥១ | លិខិតបញ្ជាក់សំណាករ៉ែ | ៣០% | ៦៩% | ១% |
| ៥២ | លិខិតបញ្ជាក់ធនធានរ៉ែ | ៣០% | ៦៩% | ១% |
| **I.២- អគ្គនាយកដ្ឋានប្រេងកាត** | | | | |
| ក. ផ្នែកអាប់ស្ទ្រីម | | | | |
| ១ | លិខិតអនុញ្ញាតលើការដាក់ពាក្យចូលដេញថ្លៃប្លុកប្រេងកាត ឬការដាក់ពាក្យស្នើសុំប្លុកប្រេងកាត | ៣០% | ៦៩% | ១% |
| ២ | លិខិតអនុញ្ញាតលើការចរចាកិច្ចព្រមព្រៀងប្រេងកាត (PSC) ឬការចរចារកិច្ចព្រមព្រៀងបុរេលទា (Prospective Agreement) | ៣០% | ៦៩% | ១% |
| ៣ | លិខិតអនុញ្ញាតលើលិខិតទទួលស្គាល់ការផ្ទេរសិទ្ធិគ្រប់គ្រង/ការប្តូរអំណាចគ្រប់គ្រងគម្រោងប្រេងកាត (Transfer of right/change of control) | ៣០% | ៦៩% | ១% |
| ៤ | លិខិតអនុញ្ញាតលើការទទួលស្គាល់ការលក់ភាគហ៊ុន ចេញ ឬចូល (Farm in/Farm out) | ៣០% | ៦៩% | ១% |
| ៥ | លិខិតអនុញ្ញាតលើលិខិតទទួលស្គាល់ការផ្លាស់ប្តូរប្រតិបត្តិករដែលទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀងប្រេងកាត (Change Operator) | ៣០% | ៦៩% | ១% |
| ៦ | លិខិតអនុញ្ញាតផលិតកម្មប្រេងកាត (Production Permit) | ៣០% | ៦៩% | ១% |
| ៧ | លិខិតអនុញ្ញាតផលិតកម្មដើម្បីអភិវឌ្ឍន៍ទីផ្សារពាណិជ្ជកម្មឧស្ម័ន | ៣០% | ៦៩% | ១% |
| ៨ | លិខិតអនុញ្ញាតបង្កើត និងដំណើរការមូលដ្ឋានផ្គត់ផ្គង់សម្ភារៈប្រតិបត្តិការ ប្រេងកាត | ៣០% | ៦៩% | ១% |
| ៩ | លិខិតពន្យារបន្ត ឬកែសម្រួលរយៈពេលចរចាកិច្ចព្រមព្រៀងប្រេងកាត | ៣០% | ៦៩% | ១% |
| ១០ | លិខិតពន្យារបន្ត ឬកែសម្រួលលើលិខិតអនុញ្ញាតចូលដំណាក់កាលទី២ ឬ ដំណាក់កាលទី៣ នៃរយៈពេលស្វែងរុករក | ៣០% | ៦៩% | ១% |
| ១១ | លិខិតពន្យារបន្ត ឬកែសម្រួលរយៈពេលស្វែងរុករកលើសពីដំណាក់កាលទី៣ នៃរយៈពេលស្វែងរុករក | ៣០% | ៦៩% | ១% |
| ១២ | លិខិតអនុញ្ញាតកែសម្រួលលើគម្រោងអភិវឌ្ឍប្រេងកាត | ៣០% | ៦៩% | ១% |
| ១៣ | លិខិតពន្យារបន្ត ឬកែសម្រួលលើលិខិតអនុញ្ញាតបន្តផលិតកម្ម (Extension of Production Permit) | ៣០% | ៦៩% | ១% |
| ១៤ | លិខិតពន្យារបន្ត ឬកែសម្រួលលើលិខិតអនុញ្ញាតពន្យាបន្តដំណើរការមូលដ្ឋានផ្គត់ផ្គង់សម្ភារៈប្រតិបត្តិការប្រេងកាត | ៣០% | ៦៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. រថ | ក. សហវ |
| ១៥ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត ឯកសារភូគព្ភសាស្ត្រ និងរូបភូគព្ភសាស្ត្រ ប្រេងកាតកម្ពុជាឆ្នាំ១៩៨៩ | ៣០% | ៦៩% | ១% |
| ១៦ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត ឯកសារវាស់ស្ទង់ ប្រព្រឹត្តកម្ម និងបកប្រែ Airborne Gravity and Magnetic ឆ្នាំ១៩៩៨ | ៣០% | ៦៩% | ១% |
| ១៧ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត កញ្ចប់ឯកសារសិក្សាស្រាវជ្រាវអតីតប្លុក I និង II ដែនសមុទ្រ ដែលធ្វើឡើងមុនឆ្នាំ ១៩៩៨ | ៣០% | ៦៩% | ១% |
| ១៨ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត កញ្ចប់ឯកសារសិក្សាស្រាវជ្រាវអតីតប្លុក III ដែនសមុទ្រ ដែលធ្វើឡើងមុនឆ្នាំ១៩៩៨ | ៣០% | ៦៩% | ១% |
| ១៩ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត កញ្ចប់ឯកសារសិក្សាស្រាវជ្រាវអតីតប្លុក IV ដែនសមុទ្រ ដែលធ្វើឡើងមុនឆ្នាំ ១៩៩៨ | ៣០% | ៦៩% | ១% |
| ២០ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត កញ្ចប់ឯកសារ Final Technical Report on Regional Study of Block I, II, III, IV, និង VII ដែនសមុទ្រកម្ពុជា ដែលបានធ្វើនៅ ឆ្នាំ ១៩៩៩ | ៣០% | ៦៩% | ១% |
| ២១ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត ទិន្នន័យរូបភូគព្ភសាស្ត្រ ( PDF File) ដែនគោក ឬ ដែនសមុទ្រ ដែលធ្វើឡើងនៅឆ្នាំ ២០០៨ និង ២០០៩ | ៣០% | ៦៩% | ១% |
| ២២ | លក់ទិន្នន័យប្រេងកាត ឯកសារវាស់ស្ទង់ ប្រព្រឹត្តកម្ម និងបកប្រែ Airborne Gravity and Magnetic ដែលធ្វើឡើងមុនឆ្នាំ ១៩៩៨ ក្នុងមួយកញ្ចប់ | ៣០% | ៦៩% | ១% |
| ២៣ | លក់ទិន្នន័យប្រេងកាត ទិន្នន័យរូបភូគព្ភសាស្ត្រដែនគោកដែលធ្វើឡើងនៅឆ្នាំ ២០០៨ និង ២០០៩ ឬ ដែនសមុទ្រមុនឆ្នាំ២០០២ ក្នុងមួយប្លុក | ៣០% | ៦៩% | ១% |
| ២៤ | ប្រាក់រង្វាន់ចុះហត្ថលេខាកិច្ចព្រមព្រៀងប្រេងកាត (Agreement Signature Bonus) | ៨០% | ១៩% | ១% |
| ២៥ | ប្រាក់រង្វាន់នៃការរកឃើញប្រេងកាត ដែលមានលក្ខណៈពាណិជ្ជកម្ម (Commercial Discovery Bonus) | ៨០% | ១៩% | ១% |
| ២៦ | ប្រាក់រង្វាន់ផលិតកម្មប្រេងកាត (Production Bonus) | ៨០% | ១៩% | ១% |
| ២៧ | សេវាកម្មមន្ត្រីចូលរួមក្នុងប្រតិបត្តិការប្រេងកាត (គិតសម្រាប់មន្ត្រី ១ រូបក្នុង ១ ថ្ងៃ) | 0% | ១០០% | 0% |
| ២៨ | លិខិតអនុញ្ញាតសម្រាប់បែបបទនាំចេញ-នាំចូលសំណាករ៉ែប្រេងកាត | ៣០% | ៦៩% | ១% |
| ២៩ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីស្វែងរុករកក្នុងដំណាក់កាលទី១/១គីឡូម៉ែត្រការ៉េ | ១០០% | 0% | 0% |
| ៣០ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីស្វែងរុករកក្នុងដំណាក់កាលទី២/១គីឡូម៉ែត្រការ៉េ | ១០០% | 0% | 0% |
| ៣១ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីស្វែងរុករកក្នុងដំណាក់កាលទី៣/១គីឡូម៉ែត្រការ៉េ | ១០០% | 0% | 0% |
| ៣២ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីស្វែងរុករកលើសពីដំណាក់កាលទី៣/១គីឡូម៉ែត្រការ៉េ | ១០០% | 0% | 0% |
| ៣៣ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីសម្រាប់ការរក្សាទុកតំបន់មានឧស្ម័ន/១គីឡូម៉ែត្រការ៉េ | ១០០% | 0% | 0% |
| ៣៤ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីសម្រាប់ផលិតកម្មប្រេងកាត/១គីឡូម៉ែត្រការ៉េ | ១០០% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. រថ | ក. សហវ |
| ខ. ផ្នែកដោនស្ទ្រីម | | | | |
| ៣៥ | លិខិតអនុញ្ញាតធ្វើការសិក្សាសមិទ្ធិលទ្ធភាពសាងសង់រោងចក្រប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត | ៥០% | ៤៩% | ១% |
| ៣៦ | លិខិតអនុញ្ញាតធ្វើការសិក្សាសមិទ្ធិលទ្ធភាពសាងសង់បំពង់បង្ហូរប្រេង ឬ ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៣៧ | លិខិតអនុញ្ញាតធ្វើការសិក្សាសមិទ្ធិលទ្ធភាពបង្កើតទីតាំងស្តុកទុក ឬលាយ ប្រេង ឬ ឧស្ម័នសម្រាប់ចែកចាយ | ៥០% | ៤៩% | ១% |
| ៣៨ | ផ្តល់អាជ្ញាប័ណ្ណប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត (សាងសង់ និងដំណើរការ) | ៥០% | ៤៩% | ១% |
| ៣៩ | ផ្តល់អាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័ន (បំពង់បង្ហូរប្រេង ឬ ឧស្ម័ន) | ៥០% | ៤៩% | ១% |
| ៤០ | ផ្តល់អាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី ១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៤១ | ផ្តល់អាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៤២ | ផ្តល់អាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះចាប់ពី ១លានលីត្រចុះ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៤៣ | ផ្តល់អាជ្ញាប័ណ្ណពាណិជ្ជកម្មប្រេង ឬ ឧស្ម័ន (នាំចេញ ឬ នាំចូលប្រេង ឬឧស្ម័ន) | ៥០% | ៤៩% | ១% |
| ៤៤ | ផ្តល់អាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័នឥន្ធនៈ (ក្រៅពីបំពង់បង្ហូរប្រេង ឬ ឧស្ម័ន) | ៥០% | ៤៩% | ១% |
| ៤៥ | ការបន្តសុពលភាពអាជ្ញាប័ណ្ណប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត (សាងសង់ និងដំណើរការ) | ៥០% | ៤៩% | ១% |
| ៤៦ | ការបន្តសុពលភាពអាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័ន (បំពង់បង្ហូរប្រេង ឬ ឧស្ម័ន) | ៥០% | ៤៩% | ១% |
| ៤៧ | ការបន្តសុពលភាពអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៤៨ | ការបន្តសុពលភាពអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី១លានលីត្រ ដល់១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៤៩ | ការបន្តសុពលភាពអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះចាប់ពី១លានលីត្រចុះ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៥០ | ការបន្តសុពលភាពអាជ្ញាប័ណ្ណពាណិជ្ជកម្មប្រេង ឬ ឧស្ម័ន (នាំចេញ ឬ នាំចូលប្រេង ឬឧស្ម័ន) | ៥០% | ៤៩% | ១% |
| ៥១ | ការបន្តសុពលភាពអាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័នឥន្ធនៈ (ក្រៅពីបំពង់បង្ហូរប្រេង ឬ ឧស្ម័ន) | ៥០% | ៤៩% | ១% |
| ៥២ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត (សាងសង់ និងដំណើរការ) | ៥០% | ៤៩% | ១% |
| ៥៣ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័ន (បំពង់បង្ហូរប្រេង ឬ ឧស្ម័ន) * | ៥០% | ៤៩% | ១% |
| ៥៤ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. រថ | ក. សហវ |
| ៥៥ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី១លានលីត្រដល់ ១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៥៦ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះក្រោម ១លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៥៧ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណពាណិជ្ជកម្មប្រេង ឬ ឧស្ម័ន (នាំចេញ ឬ នាំចូលប្រេង ឬឧស្ម័ន) | ៥០% | ៤៩% | ១% |
| ៥៨ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័នឥន្ធនៈ (ក្រៅពីបំពង់បង្ហូរប្រេង ឬ ឧស្ម័ន) | ៥០% | ៤៩% | ១% |
| ៥៩ | លិខិតអនុញ្ញាតសម្រាប់បែបបទនាំចូល ឬ នាំចេញប្រេង ឬ ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៦០ | វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត | ៥០% | ៤៩% | ១% |
| ៦១ | វិញ្ញាបនបត្រអនុញ្ញាតដំណើរការបំពង់បង្ហូរប្រេង ឬ ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៦២ | វិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះ លើសពី ១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៦៣ | វិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះចាប់ពី១លាន លីត្រដល់១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៦៤ | វិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះក្រោម ១លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៦៥ | កម្រៃការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត | ៥០% | ៤៩% | ១% |
| ៦៦ | កម្រៃការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការបំពង់បង្ហូរប្រេង ឬ ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៦៧ | កម្រៃការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែល មានចំណុះ លើសពី១០លានលីត្រឡើង ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៦៨ | កម្រៃការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែល មានចំណុះចាប់ពី១លានលីត្រដល់១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៦៩ | កម្រៃការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែល មានចំណុះក្រោម ១លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៥០% | ៤៩% | ១% |
| ៧០ | ការអនុញ្ញាតផ្សេងៗពាក់ព័ន្ធនឹងស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈលើលិខិតបញ្ជាក់បច្ចេកទេស សុវត្ថិភាពនៃបង្កើតស្ថានីយប្រេង ឬឧស្ម័នឥន្ធនៈ | ៣០% | ៦៩% | ១% |
| ៧១ | ការអនុញ្ញាតផ្សេងៗពាក់ព័ន្ធនឹងស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈលើវិញ្ញាបនបត្រអនុញ្ញាត ដំណើរការស្ថានីយប្រេង ឬឧស្ម័នឥន្ធនៈ | ៣០% | ៦៩% | ១% |
| ៧២ | ការអនុញ្ញាតផ្សេងៗពាក់ព័ន្ធនឹងស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈលើការបន្តសុពលភាព វិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេង ឬឧស្ម័នឥន្ធនៈ | ៣០% | ៦៩% | ១% |
| ៧៣ | ការអនុញ្ញាតផ្សេងៗពាក់ព័ន្ធនឹងស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈលើលិខិតអនុញ្ញាតកែសម្រួល ស្ថានីយប្រេង ឬឧស្ម័នឥន្ធនៈ | ៣០% | ៦៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. រថ | ក. សហវ |
| ៧៤ | ការអនុញ្ញាតផ្សេងៗពាក់ព័ន្ធនឹងស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈលើលិខិតអនុញ្ញាតផ្ទេរម្ចាស់ស្ថានីយប្រេង ឬឧស្ម័នឥន្ធនៈ | ៥០% | ៤៩% | ១% |
| **I.៣- អគ្គនាយកដ្ឋានថាមពល** | | | | |
| **ក. ការអនុញ្ញាតវិនិយោគសម្រាប់ផលិតកម្មអគ្គិសនី (សម្រាប់តែការវិនិយោគឯកជន)** | | | | |
| ១ | ចេញប្រកាស ឬចេញលិខិតអនុញ្ញាតសម្រាប់ផលិតកម្មអគ្គិសនីដោយប្រើប្រេងម៉ាស៊ូត (DO) ប្រេងខ្មៅ (HFO) វារីអគ្គិសនី ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត ដែលមានអានុភាពទាបជាង ១ ០០០ គីឡូវ៉ាត់ (P<១ ០០០ kW) | ៥០% | ៤៩% | ១% |
| ២ | ចេញប្រកាសអនុញ្ញាត ឬចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងឱ្យវិនិយោគស្ថានីយអគ្គិសនីដោយប្រើប្រេងម៉ាស៊ូត (DO) ប្រេងខ្មៅ (HFO) ធ្យូងថ្ម វារីអគ្គិសនី ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត ដែលមានអានុភាពចាប់ពី ១ ០០០ គីឡូវ៉ាត់ ឡើងទៅ (P≥១ | ៥០% | ៤៩% | ១% |
| **ខ. ការអនុញ្ញាតវិនិយោគសម្រាប់បណ្តាញបញ្ជូន និងចែកចាយអគ្គិសនី (សម្រាប់តែការវិនិយោគឯកជន)** | | | | |
| ៣ | ចេញប្រកាសអនុញ្ញាត ឬចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងវិនិយោគអគ្គិសនីសម្រាប់បណ្តាញអគ្គិសនី តង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល ឬ ២៣០ គីឡូវ៉ុល | ៥០% | ៤៩% | ១% |
| ៤ | ចេញប្រកាសអនុញ្ញាតវិនិយោគអគ្គិសនីសម្រាប់បណ្តាញអគ្គិសនីតង់ស្យុងមធ្យម ២២ គីឡូវ៉ុល ឬ ៣៥ គីឡូវ៉ុល | ៥០% | ៤៩% | ១% |
| ៥ | ចេញប្រកាស ឬចេញលិខិតអនុញ្ញាតវិនិយោគអគ្គិសនីសម្រាប់បណ្តាញអគ្គិសនី តង់ស្យុងទាប ០.៤ គីឡូវ៉ុល ឬ ៣៨០វ៉ុល | ៥០% | ៤៩% | ១% |
| **គ. ការអនុញ្ញាតផ្ទេរសិទ្ធិវិនិយោគសម្រាប់ផលិតកម្ម បណ្តាញបញ្ជូន និងចែកចាយអគ្គិសនី (សម្រាប់តែការវិនិយោគឯកជន)** | | | | |
| ៦ | ចេញប្រកាសអនុញ្ញាតឱ្យផ្ទេរសិទ្ធិការវិនិយោគផលិតកម្មថាមពលអគ្គិសនី | ៥០% | ៤៩% | ១% |
| ៧ | ចេញប្រកាសអនុញ្ញាតឱ្យផ្ទេរសិទ្ធិការវិនិយោគខ្សែបញ្ជូន និងចែកចាយថាមពលអគ្គិសនី | ៥០% | ៤៩% | ១% |
| **ឃ. ការអនុញ្ញាតឱ្យសិក្សា និងពន្យារពេលសិក្សាគម្រោងផលិតកម្ម បណ្តាញបញ្ជូន និងចែកចាយអគ្គិសនី (សម្រាប់តែការវិនិយោគឯកជន)** | | | | |
| ៨ | ចេញលិខិតអនុញ្ញាត ឬអនុស្សារណៈយោគយល់គ្នា (MOU) ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងផលិតកម្មអគ្គិសនី ដោយប្រើប្រេងឥន្ធនៈ ធ្យូងថ្ម វារីអគ្គិសនី ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត | ៥០% | ៤៩% | ១% |
| ៩ | ចេញលិខិតពន្យារពេលលើលិខិតអនុញ្ញាត ឬអនុស្សារណៈយោគយល់គ្នា (MOU) ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងផលិតកម្មអគ្គិសនីដោយប្រើប្រេងឥន្ធនៈ ធ្យូងថ្ម វារីអគ្គិសនី ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត | ៥០% | ៤៩% | ១% |
| ១០ | ចេញលិខិតអនុញ្ញាត ឬអនុស្សារណៈយោគយល់គ្នា (MOU) ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងខ្សែបញ្ជូន និងចែកចាយថាមពលអគ្គិសនី | ៥០% | ៤៩% | ១% |
| ១១ | ចេញលិខិតពន្យារពេលលើលិខិតអនុញ្ញាត ឬអនុស្សារណៈយោគយល់គ្នា (MOU) ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងខ្សែបញ្ជូន និងចែកចាយថាមពលអគ្គិសនី | ៥០% | ៤៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. រថ | ក. សហវ |
| **II. ការពិន័យអន្តរការណ៍ជាច្បាស់** | | | | |
| ១ | ករណីផុតសុពលភាពអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម | ៥០% | ៤៩% | ១% |
| ២ | ករណីផុតសុពលភាពអាជ្ញាប័ណ្ណស្វែងរុករក | ៥០% | ៤៩% | ១% |
| ៣ | ករណីផុតសុពលភាពអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ | ៥០% | ៤៩% | ១% |
| ៤ | ករណីបង់សួយសារធនធានរ៉ែមិនទាន់កាលកំណត់ | ៥០% | ៤៩% | ១% |
| ៥ | ករណីដំណើរការដោយអាជ្ញាប័ណ្ណធនធានរ៉ែ ផុតសុពលភាព | | | |
| | - អាជ្ញាប័ណ្ណសិប្បកម្ម | ៥០% | ៤៩% | ១% |
| | - អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម | ៥០% | ៤៩% | ១% |
| | - អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ | ៥០% | ៤៩% | ១% |
| | - អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ | ៥០% | ៤៩% | ១% |